ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៥ មាត្រា៦ មាត្រា៧ មាត្រា៨ និងមាត្រា៩ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- បានឃើញអនុក្រឹត្យលេខ ១៤២ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## សម្រេច

**មាត្រាមួយ .-**

មាត្រា៥ មាត្រា៦ មាត្រា៧ មាត្រា៨ និងមាត្រា៩ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ត្រូវបានធ្វើការកែសម្រួលដូចខាងក្រោម៖

**មាត្រា៥ .- ថ្មី**

គ.ស.ហ. ត្រូវជួបប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ដោយមានការប្រគល់សិទ្ធិពីប្រធាន។

គ.ស.ហ. មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឯកជន ឬភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិនានា ដើម្បីចូលរួមពិភាក្សា និងផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ គ.ស.ហ. តាមការចាំបាច់។

**មាត្រា៦ .- ថ្មី**

គ.ស.ហ. មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារមួយ ឬច្រើន ដើម្បីជួយ គ.ស.ហ. បំពេញភារកិច្ចតាមដាន វាយតម្លៃ សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួង ស្ថាប័នអនុវត្តច្បាប់ លើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ សមាជិកទាំងនោះអាចត្រូវបានជ្រើសរើសចេញពីក្រសួង ស្ថាប័នតំណាងនៅក្នុង គ.ស.ហ. និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

**មាត្រា៧ .- ថ្មី**

គ.ស.ហ. មានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាលេខាធិការដ្ឋានសម្រាប់គាំទ្រដល់ការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។

តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ស.ហ.។

**មាត្រា៨ .- ថ្មី**

ការចំណាយលើការបំពេញតួនាទី ភារកិច្ច និងកិច្ចដំណើរការការងាររបស់ គ.ស.ហ. និងយន្តការចំណុះឱ្យ គ.ស.ហ. ត្រូវប្រើប្រាស់កញ្ចប់ថវិការបស់ធនាគារជាតិ។

គ.ស.ហ. មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងនូវមូលនិធិ អំណោយ ធនធាន និងថវិកាដែលទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

សមាសភាពនៃ គ.ស.ហ. និងសមាសភាពនៃយន្តការចំណុះ គ.ស.ហ. អាចទទួលបានប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការបំពេញមុខងារក្នុងក្របខ័ណ្ឌនៃ គ.ស.ហ.។ ការចំណាយលើការបើកប្រាក់រង្វាន់លើកទឹកចិត្តនេះ អាចប្រើប្រាស់ថវិការបស់ធនាគារជាតិ និង/ឬថវិកាដែលទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

**មាត្រា៩ .- ថ្មី**

គ.ស.ហ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ នៅក្នុងការបំពេញការងាររបស់ខ្លួន។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៤ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**និងជាប្រធាន គ.ស.ហ.**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ